**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨. អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ ស្ដីពីការប្ដូរឈ្មោះនាយកដ្ឋានជលផលទៅជារដ្ឋបាលជលផល
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៨ ខែមករា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទសម្រាប់ធ្វើអាជីវកម្មនេសាទ ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងធានាតម្លាភាពក្នុងការវិនិយោគ ការដេញថ្លៃ ការជួលកន្លែងនេសាទ ការប្រមូលចំណូលថវិកា និងធានាការគ្រប់គ្រង ការប្រើប្រាស់ ការធ្វើអាជីវកម្ម និងការអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តលើដែននេសាទទឹកសាប និងដែននេសាទសមុទ្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែកន្លែងនេសាទគ្រួសារ សហគមន៍នេសាទ និងកន្លែងអភិរក្សជលផល ។

**មាត្រា៤.-**

វាក្យសព្ទ ដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ ៖

**ឡូត៍នេសាទ** សំដៅដល់ចំណោត់ថ្នាក់នៃដែននេសាទទឹកសាបដែលផ្តល់នូវផលនេសាទ ហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់ដែលមានប្រព័ន្ធបឹង ព្រែក ព្រៃលិចទឹក ធនធានជលផល និងជីវចម្រុះ ដែលកំណត់នូវការកកើត និងរីកធំធាត់របស់មច្ឆជាតិ វារីសត្វ និងវារីរុក្ខជាតិ ហើយនឹងត្រូវបានកំណត់នូវទីតាំង និងពេលវេលាអាជីវកម្មជាក់លាក់ ដោយមិនជះឥទ្ធិពលដល់ទីតាំងដទៃទៀត ។

**ការវិនិយោគអាជីវកម្មឡូត៍នេសាទ** សំដៅដល់ការវិនិយោគដោយឡែកមួយសម្រាប់ការស្តារ និងការលើកស្ទួយធនធានជលផលនៅក្នុងនាទីឡូត៍នេសាទដែលខ្សោយផលិតភាព រួមមាន ការដាំ ការថែរក្សានាទីព្រៃលិចទឹក ការស្តារឱ្យមានជម្រៅតាមប្រព័ន្ធបឹងព្រែក ក្នុងគោលបំណងបង្កើនទិន្នផល ផលត្រី ។

**ភាពខ្សោយផលិតភាព** សំដៅដល់ភាពទ្រុឌទ្រោម រេចរិល ខ្សត់ខ្សោយធនធាន និងមិនផ្តល់ទិន្នផលខ្ពស់ ។

**ការដេញថ្លៃ** សំដៅដល់ការចូលរួម និងហ៊ានឱ្យថ្លៃខ្ពស់ជាងគេ ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលបន្ថែមពីលើថ្លៃមូលដ្ឋានដែលសមត្ថកិច្ចជំនាញបានកំណត់រួច ។

**ថ្លៃព្យួរឡូត៍នេសាទ** សំដៅដល់ថ្លៃឈ្នួលជាមូលដ្ឋានរបស់ឡូត៍នេសាទ សម្រាប់ដាក់ដេញថ្លៃជាសាធារណៈ និងកំណត់ដាក់ឱ្យដេញថ្លៃឡើង ។

**ប្រាក់ធានាសន្ដារ** សំដៅដល់ប្រាក់ដែលរូបវន្តបុគ្គល ឬនីតិបុគ្គលដាក់តម្កល់ទុកឱ្យសមត្ថកិច្ចជំនាញសម្រាប់ធានាការធ្វើអាជីវកម្មនេសាទ ហើយដែលប្រាក់នេះនឹងបង្វែរបង្គ្រប់ថ្លៃឈ្នួលឡូត៍នៅរដូវនេសាទបន្ទាប់។

**រូបវន្តបុគ្គល** មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។

**នីតិបុគ្គល** ក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិ និងកាតព្វកិច្ច។

**ការនេសាទជាលក្ខណៈគ្រួសារ** សំដៅដល់ការនេសាទទ្រង់ទ្រាយតូចដែលប្រើប្រាស់ឧបករណ៍មានលក្ខណៈទោល។ ការនេសាទជាលក្ខណៈគ្រួសារក៏ជាការនេសាទដែលមានលក្ខណៈជាប្រពៃណី ហើយជាទូទៅពុំមែនសម្រាប់គោលបំណងធ្វើពាណិជ្ជកម្មទេ។

**ការនេសាទជាលក្ខណៈសិប្បកម្ម** សំដៅដល់ការនេសាទទ្រង់ទ្រាយមធ្យម ប្រើប្រាស់ឧបករណ៍នេសាទមានលក្ខណៈទោល ឬឧបករណ៍នេសាទមានលក្ខណៈជាបរិក្ខារ ហើយធ្វើសកម្មភាពនេសាទដោយកម្លាំងពលកម្មម្នាក់ ឬច្រើននាក់។ ក៏ប៉ុន្តែក្នុងការធ្វើនេសាទដោយកម្លាំងពលកម្មច្រើននាក់ក៏ដោយ ក៏សកម្មភាពនោះមិនអាចបែងចែកក្រុមដោយឡែកពីគ្នាច្បាស់លាស់ឡើយ ហើយថែមទាំងអនុវត្តសកម្មភាពក្នុងពេលព្រមគ្នា។

**ការនេសាទជាលក្ខណៈឧស្សាហកម្ម** សំដៅដល់ការនេសាទទ្រង់ទ្រាយធំដែលប្រើប្រាស់ឧបករណ៍នេសាទមានលក្ខណៈជាបរិក្ខារ ហើយធ្វើសកម្មភាពនេសាទដោយប្រើប្រាស់កម្លាំងពលកម្មតាមក្រុមដាច់ដោយឡែកពីគ្នា ហើយក្រុមនីមួយៗអាចប្រើពេលវេលាពលកម្មខុសគ្នា។

## ជំពូកទី២
## គោលការណ៍នៃការធ្វើអាជីវកម្មឡូត៍នេសាទ

**មាត្រា៥.-**

ការធ្វើអាជីវកម្មឡូត៍នេសាទ ត្រូវមានអ្នកជំនាញបច្ចេកទេសនេសាទម្នាក់ដែលមានសញ្ញាបត្រមធ្យមជលផលឡើងទៅ ដើម្បីធ្វើគម្រោងផែនការគ្រប់គ្រងការធ្វើអាជីវកម្មឡូត៍នេសាទ ចូលរួមអភិរក្សធនធានជលផល តាមដានអង្កេត ប្រមូលទិន្នន័យ និងធ្វើរបាយការណ៍បូកសរុបលទ្ធផល នៅចុងបញ្ចប់រដូវនេសាទនីមួយៗ។

**មាត្រា៦.-**

អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទអាចផ្ទេរសិទ្ធិកាន់កាប់ឡូត៍នេសាទឱ្យសហពទ្ធ ឬកូន ឬតំណាងស្របច្បាប់ ដើម្បីទទួលខុសត្រូវជំនួស ដោយមានការយល់ព្រមពីរដ្ឋបាលជលផលថ្នាក់កណ្ដាល។ ក្នុងករណីដែលអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទនោះទទួលមរណភាព ឬបាត់បង់សមត្ថភាព ដោយមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលជលផលត្រូវរៀបចំសំណុំបែបបទដើម្បីផ្ទេរទៅឱ្យសហពទ្ធ ឬកូន ឬតំណាងស្របច្បាប់ទទួលខុសត្រូវជំនួសតាមការស្នើសុំ។

**មាត្រា៧.-**

ការធ្វើអាជីវកម្មឡូត៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មឡូត៍នេសាទ ត្រូវគោរពដាច់ខាតតាមសៀវភៅបន្ទុកឡូត៍នេសាទ។

គំរូសៀវភៅបន្ទុកឡូត៍នេសាទដែលបានរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៨.-**

អ្នកដែលទទួលបានសិទ្ធិកាន់កាប់ឡូត៍នេសាទ មិនអាចយកឡូត៍នេសាទទាំងមូល ឬផ្នែកណាមួយនៃឡូត៍នេសាទ ដែលបានទទួលសិទ្ធិកាន់កាប់ ទៅជួលឱ្យអ្នកដទៃឡើយ ។ ក្នុងករណីមានការរំលោភបទប្បញ្ញត្តិនេះ ត្រូវនិរាករណ៍សិទ្ធិនៃការកាន់កាប់ឡូត៍នេសាទនោះ ។

## ជំពូកទី៣
## នីតិវិធីនៃការវិនិយោគអាជីវកម្មឡូត៍នេសាទ

**មាត្រា៩.-**

រដ្ឋបាលជលផលថ្នាក់កណ្តាល ត្រូវសិក្សាពីចំនួនឡូត៍នេសាទដែលខ្សោយផលិតភាព និងត្រូវកសាងផែនការវិនិយោគតាមឡូត៍នេសាទនីមួយៗ ដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស្នើសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលសម្រេចមុនពេលដាក់ឱ្យវិនិយោគ ។

**មាត្រា១០.-**

ក្រោយពេលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល រដ្ឋបាលជលផលត្រូវធ្វើសេចក្តីជូនដំណឹងអំពីការដេញថ្លៃជាសាធារណៈ និងបិទផ្សាយនៅរដ្ឋបាលជលផលថ្នាក់កណ្តាល ខណ្ឌរដ្ឋបាលជលផល សាលារាជធានី ខេត្ត ឱ្យបានយ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនពេលបើកសំបុត្រដេញថ្លៃវិនិយោគ ។

**មាត្រា១១.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងវិនិយោគអាជីវកម្មឡូត៍នេសាទ ត្រូវធ្វើពាក្យសុំមករដ្ឋបាលជលផល តាមរយៈខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផលសាមី ដោយបញ្ជាក់គម្រោងផែនការវិនិយោគ ទុនវិនិយោគក្នុងក្របខណ្ឌអភិវឌ្ឍធនធានជលផល ។ រយៈពេលនៃការវិនិយោគអាជីវកម្មឡូត៍នេសាទ ត្រូវគោរពតាមផែនការវិនិយោគឡូត៍នេសាទនីមួយៗដែលសម្រេចដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ទុនវិនិយោគសម្រាប់ធ្វើការអភិវឌ្ឍនិងកែលំអ មិនរាប់បញ្ចូលថ្លៃឈ្នួលឡូត៍នេសាទដែលត្រូវបង់ជូនរដ្ឋឡើយ ។

**មាត្រា១២.-**

ការស្នើសុំវិនិយោគអាជីវកម្មឡូត៍នេសាទ ត្រូវមានសំណុំលិខិតភ្ជាប់មកជាមួយដូចខាងក្រោម ៖

ក. ចំពោះរូបវន្តបុគ្គល ៖

១- ពាក្យស្នើសុំវិនិយោគអាជីវកម្មឡូត៍នេសាទមានបិទតែមប្រើសារពើពន្ធ និងបិទរូបថត (៤ x ៦) ចំនួន០៣ ច្បាប់

២- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ និងបណ្ណគ្រួសារថតចម្លងដោយមានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់ ចំនួន០៣ ច្បាប់

៣- លិខិតបញ្ជាក់សមត្ថភាពជំនាញខាងធ្វើអាជីវកម្មឡូត៍នេសាទចេញដោយរដ្ឋបាលជលផលតាមរយៈខណ្ឌរដ្ឋបាលជលផលដែលសាមីជនរស់នៅ ចំនួន០១ ច្បាប់

៤- គម្រោងផែនការស្នើសុំវិនិយោគដាក់ក្នុងស្រោមសំបុត្របិទជិត ចំនួន០៣ ច្បាប់

៥- កិច្ចសន្យាវិនិយោគឡូត៍នេសាទ ចំនួន០៣ ច្បាប់

៦- ប្រកាសឥណទានរបស់ធនាគារអំពីប្រាក់ធានាបណ្តោះអាសន្ន
១/៣ ( មួយភាគបី) នៃថ្លៃព្យួរឡូត៍នេសាទ ចំនួន០៣ ច្បាប់

៧- កិច្ចសន្យាប្រគល់ប្រាក់ធានាស្មោរ៥០( ហាសិប ) ភាគរយ នៃថ្លៃដែលដេញបាន ចំនួន០៣ ច្បាប់

៨- កិច្ចសន្យាស្តីពីការគោរពឱ្យបានត្រឹមត្រូវតាមសៀវភៅបន្ទុក និង
លិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មឡូត៍នេសាទ ចំនួន០៣ ច្បាប់ ។

ខ. ចំពោះនីតិបុគ្គលត្រូវភ្ជាប់បន្ថែម ៖

១- លិខិតប្រគល់សិទ្ធិជាតំណាងស្របច្បាប់ ចំនួន ០៣ ច្បាប់

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មចេញដោយ
ក្រសួងពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់

៣- លក្ខន្តិកៈក្រុមហ៊ុនមាននីត្យានុកូលភាព ចំនួន ០៣ ច្បាប់

៤- បណ្ណប៉ាតង់ ចំនួន ០៣ ច្បាប់ ។

**មាត្រា១៣.-**

មិនអនុញ្ញាត ឬមិនទទួលពាក្យស្នើសុំវិនិយោគអាជីវកម្មឡូត៍នេសាទចំពោះ ៖

- មន្ត្រីរាជការ
- រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលកន្លងមកមិនបានអនុវត្តតាមកិច្ចសន្យាវិនិយោគ ឬធ្លាប់បានប្រព្រឹត្តបទល្មើសនេសាទមានលក្ខណៈធ្ងន់ធ្ងរ ឬនៅជំពាក់ថ្លៃឈ្នួលឡូត៍នេសាទ ឬប្រាក់បំណុលរដ្ឋផ្សេងៗ ។

**មាត្រា១៤.-**

ការប្រគល់ឡូត៍នេសាទឱ្យធ្វើការវិនិយោគ ត្រូវស្ថិតនៅក្រោមការចាត់ចែងរបស់គណៈកម្មការវិនិយោគឡូត៍នេសាទ ដែលមានសមាសភាពដូចខាងក្រោម ៖

- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង ប្រធាន
- ប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ឬតំណាង អនុប្រធាន
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង សមាជិក
- ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង សមាជិក
- ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតំណាង សមាជិក
- នាយអធិការដ្ឋានរដ្ឋបាលជលផលសាមី ឬតំណាង សមាជិក
- នាយខណ្ឌរដ្ឋបាលជលផលសាមី ឬតំណាង សមាជិក
- ប្រធាននាយកដ្ឋានកិច្ចការជលផល លេខាធិការ

សមាសភាពជាក់ស្តែងនៃគណៈកម្មការវិនិយោគឡូត៍នេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា១៥.–**

គណៈកម្មការវិនិយោគឡូត៍នេសាទត្រូវពិនិត្យ និងធ្វើការវាយតម្លៃលើចរិតលក្ខណៈបច្ចេកទេសអាជីវកម្មនេសាទ ហើយកំណត់ចំនួនឯកសារវិនិយោគបានការ ព្រមទាំងកំណត់ពេលបើកស្រោមសំបុត្រសម្រេច ។

បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់តាមនីតិវិធីនៃការស្នើសុំវិនិយោគ និងក្រោយពីទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញសេចក្តីសម្រេចប្រគល់សិទ្ធិកាន់កាប់ឡូត៍នេសាទឱ្យធ្វើការវិនិយោគ ។

**មាត្រា១៦.–**

វិនិយោគិនដែលទទួលបានសិទ្ធិវិនិយោគ ត្រូវធ្វើគម្រោងផែនការវិនិយោគអាជីវកម្មឡូត៍នេសាទ ដែលទទួលបានការឯកភាពពីរដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបញ្ចូលក្នុងផែនការសកម្មភាពអភិវឌ្ឍមូលដ្ឋាន ។

## ជំពូកទី៤
## នីតិវិធីនៃការដេញថ្លៃឡូត៍នេសាទ

**មាត្រា១៧.–**

ដើម្បីដេញថ្លៃឡូត៍នេសាទ រដ្ឋបាលជលផលត្រូវធ្វើសេចក្តីជូនដំណឹងអំពីការដេញថ្លៃជាសាធារណៈ និងបិទផ្សាយនៅរដ្ឋបាលជលផលថ្នាក់កណ្តាល ខណ្ឌរដ្ឋបាលជលផល សាលារាជធានី ខេត្ត ឱ្យបានយ៉ាងតិច៣០(សាមសិប)ថ្ងៃ មុនពេលដេញថ្លៃ ហើយត្រូវបញ្ជាក់អំពី ៖

- ទីតាំងឡូត៍នេសាទដែលត្រូវដាក់ឱ្យដេញថ្លៃ
- ថ្លៃព្យួរឡូត៍នេសាទក្រោយពីបានពិគ្រោះយោបល់ជាមួយតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រាក់ធានាបណ្តោះអាសន្ន
- ទីកន្លែង និងពេលវេលាដែលត្រូវដេញថ្លៃ ។

**មាត្រា១៨.–**

ការដេញថ្លៃឡូត៍នេសាទ ត្រូវប្រព្រឹត្តទៅនៅសាលារាជធានី ខេត្ត ហើយស្ថិតនៅក្រោមការចាត់ចែងរបស់គណៈកម្មការដេញថ្លៃឡូត៍នេសាទដែលមានសមាសភាពដូចខាងក្រោម ៖

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង ប្រធាន
- ប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ឬតំណាង អនុប្រធាន
- តំណាងប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង សមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ឬតំណាង សមាជិក
- នាយកដ្ឋានរដ្ឋបាលជលផល ឬតំណាង សមាជិក

- ប្រធាននាយកដ្ឋានកិច្ចការជលផល សមាជិក
- នាយខណ្ឌ ឬនាយរងខណ្ឌរដ្ឋបាលជលផល សមាជិក និងជាលេខាធិការ ។

សមាសភាពជាក់ស្តែងនៃគណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវកំណត់ដោយដីការបស់រាជធានី ខេត្ត ។

**មាត្រា១៩.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលមានប្រាក់ទុន មធ្យោបាយ និងជំនាញខាងធ្វើអាជីវកម្មឡូត៍នេសាទ ហើយដែលមិនត្រូវបានប្រាសចាកសិទ្ធិដូចមានចែងក្នុងមាត្រា២១នៃអនុក្រឹត្យនេះ មានសិទ្ធិចូលដេញថ្លៃឡូត៍នេសាទបាននៅតាមបណ្តារាជធានី ខេត្ត ។

**មាត្រា២០.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងចូលដេញថ្លៃ ត្រូវដាក់ពាក្យសុំដេញថ្លៃធ្វើអាជីវកម្មឡូត៍នេសាទយ៉ាងយូរបំផុត១០(ដប់) ថ្ងៃ មុនពេលដេញថ្លៃ នៅខណ្ឌរដ្ឋបាលជលផលដែលមានឡូត៍នេសាទដាក់ឱ្យដេញថ្លៃ ។

ពាក្យសុំដេញថ្លៃខាងលើនេះ ត្រូវមានសំណុំលិខិតភ្ជាប់មកជាមួយដូចខាងក្រោម ៖

ក. ចំពោះរូបវន្តបុគ្គល ៖

១- ពាក្យសុំចូលដេញថ្លៃឡូត៍នេសាទនីមួយៗ ដែលមានបិទតែមប្រិ៍សារពើពន្ធ ចំនួន ០៣ ច្បាប់

២- រូបថត ៤ x ៦ ចំនួន ០៣ សន្លឹក

៣- ឯកសារដូចមានក្នុងចំណុច ២ ៣ ៦ ៧ និង៨ កថាខណ្ឌ ក មាត្រា១២ នៃអនុក្រឹត្យនេះ ។

ខ. ចំពោះនីតិបុគ្គល ត្រូវភ្ជាប់បន្ថែមដូចចំណុច ខ មាត្រា១២ នៃអនុក្រឹត្យនេះ ។

**មាត្រា២១.-**

មិនអនុញ្ញាតឱ្យចូលដេញថ្លៃឡូត៍នេសាទចំពោះ ៖

- មន្ត្រីរាជការ
- រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលធ្លាប់ដេញថ្លៃបានហើយមិនគោរពកិច្ចសន្យា ធ្លាប់បានប្រព្រឹត្តបទល្មើសនេសាទមានលក្ខណៈធ្ងន់ធ្ងរ ឬនៅជំពាក់ថ្លៃឈ្នួលឡូត៍នេសាទ ឬប្រាក់បំណុលរដ្ឋផ្សេងៗ ។

**មាត្រា២២.-**

ការដេញថ្លៃឡូត៍នេសាទមួយលើកៗ ត្រូវបានកំណត់សម្រាប់ឱ្យធ្វើអាជីវកម្មនេសាទក្នុងរយៈពេលពីររដូវនេសាទជាប់គ្នា ។

**មាត្រា២៣.-**

នីតិវិធីនៃការដេញថ្លៃត្រូវអនុវត្តដូចខាងក្រោម ៖

នៅពេលចាប់ផ្តើមការដេញថ្លៃឡូត៍នេសាទនីមួយៗ គណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវប្រកាសឈ្មោះអ្នកមានសិទ្ធិចូលដេញថ្លៃ ទីតាំងឡូត៍នេសាទ និងថ្លៃឈ្នួលឡូត៍នេសាទដែលកំណត់ដាក់ឱ្យដេញថ្លៃ ព្រមទាំងអានសៀវភៅបន្ទុកឡូត៍នេសាទ ។

នីតិវិធីនៃការដេញថ្លៃ ត្រូវអនុវត្តតាមរូបភាពដេញថ្លៃឡើង ដោយដាក់ក្នុងស្រោមសំបុត្របិទជិតមិនជ្រើសរើសឈ្មោះ ៖

-លើកទី ១ : ត្រូវដេញថ្លៃខ្ពស់ជាងថ្លៃកំណត់ដាក់ឱ្យដេញថ្លៃ ។ អ្នកដែលដាក់ថ្លៃទាបជាងនេះ មិនមានសិទ្ធិចូលដេញថ្លៃនៅលើកទី២ទៀតបានទេ ។/

-លើកទី ២ : ត្រូវដេញថ្លៃបន្ត ចាប់ពីថ្លៃដែលខ្ពស់ជាងគេនៅលើកទី១ ។ អ្នកដែលដាក់ថ្លៃទាបជាងនេះ ពុំមានសិទ្ធិចូលដេញថ្លៃនៅលើកទី៣ទៀតបានឡើយ ។

-លើកទី ៣ : ត្រូវដេញថ្លៃបន្ត ចាប់ពីថ្លៃខ្ពស់ជាងគេនៅលើកទី២ ហើយអ្នកដែលហ៊ានឱ្យថ្លៃខ្ពស់ជាងគេ ត្រូវបានប្រកាសទទួលស្គាល់ថាជាអ្នកដេញថ្លៃបានជាបណ្តោះអាសន្ន ។

ក្នុងករណីដែលទឹកប្រាក់ដេញថ្លៃខ្ពស់ជាងគេនៅលើកទី៣នេះស្មើគ្នាចាប់ពី០២នាក់ឡើងទៅ គណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវរៀបចំធ្វើការដេញថ្លៃតាមនីតិវិធីខាងលើជាបន្តរហូតនៅសល់តែអ្នកហ៊ានឱ្យថ្លៃខ្ពស់ជាងគេតែម្នាក់ ។ គណៈកម្មការដេញថ្លៃឡូត៍នេសាទត្រូវប្រកាសនិងបង្ហាញជាសាធារណៈនូវលទ្ធផលនៃការដេញថ្លៃរាល់ពេលបើកស្រោមសំបុត្រដេញថ្លៃមួយលើក១ ។

## មាត្រា២៤._

ក្នុងករណីដែលមានអ្នកចូលដេញថ្លៃមានតែម្នាក់ គណៈកម្មការដេញថ្លៃឡូត៍នេសាទមានសិទ្ធិចរចាពិគ្រោះថ្លៃជាមួយនឹងអ្នកចូលដេញថ្លៃដោយត្រូវមានថ្លៃលើសពីថ្លៃព្យួរឡូត៍នេសាទ ។

នៅពេលដេញថ្លៃ បើមានឡូត៍នេសាទខ្លះដែលគ្មានអ្នកដាក់ពាក្យចូលដេញថ្លៃ គណៈកម្មការដេញថ្លៃឡូត៍នេសាទត្រូវកំណត់ថ្លៃព្យួរឡូត៍នេសាទម្តងទៀតជាលើកចុងក្រោយឱ្យបានសមស្រប និងកំណត់ពេលវេលាត្រឹម១៥(ដប់ប្រាំ) ថ្ងៃក្រោយពេលប្រកាសជូនដំណឹង ។

## មាត្រា២៥._

រាល់ការដេញថ្លៃបាន ត្រូវចាត់ទុកជាមោឃៈ ក្នុងករណីណាមួយដូចខាងក្រោម ៖

១- ការដេញថ្លៃឡូត៍នេសាទដោយមិនបានធ្វើសេចក្តីជូនដំណឹង ដូចមានចែងក្នុងមាត្រា១៧ ឬដេញថ្លៃខុសពីសេចក្តីបញ្ជាក់ក្នុងសេចក្តីជូនដំណឹង ។

២- មានភស្តុតាងបញ្ជាក់ថា អ្នកដេញថ្លៃបាននោះ បានឃុបឃិតជាមួយអ្នកដទៃទៀត ឬមានកលល្បិចធ្វើឱ្យការដេញថ្លៃនោះមានតម្លៃថោក ចាប់ពីពេលដេញថ្លៃរហូតដល់មុនពេលចេញសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣- អ្នកដេញថ្លៃបានហើយនោះ មិនបានបង់ប្រាក់ធានាស្ថាពរនៃថ្លៃដេញបានឱ្យបានគ្រប់ចំនួន៥០(ហាសិប) ភាគរយ ក្រោយពេលដេញថ្លៃ១៥(ដប់ប្រាំ) ថ្ងៃ ។

ក្នុងករណីណាមួយខាងលើនេះកើតមានឡើង គណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវរៀបចំដេញថ្លៃឡូត៍នេសាទនោះសាជាថ្មី ក្រោយពីបានធ្វើសេចក្តីជូនដំណឹងចំនួន១៥(ដប់ប្រាំ) ថ្ងៃរួចមក ។

រូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលមានបំណងដេញថ្លៃ ត្រូវដាក់សំណុំបែបបទសុំចូលដេញថ្លៃយ៉ាងយូរបំផុតឱ្យបាន ២(ពីរ) ថ្ងៃ មុនពេលដេញថ្លៃ ។

## មាត្រា២៦._

ក្នុងករណីដែលអ្នកមានឈ្មោះចូលដេញថ្លៃអវត្តមានដោយមូលហេតុចាំបាច់ណាមួយ ត្រូវប្រគល់សិទ្ធិឱ្យតំណាងរបស់ខ្លួនម្នាក់ចូលដេញថ្លៃជំនួស ប៉ុន្តែលិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់ ឬមេធាវី ឬសារការី ។ លិខិតប្រគល់សិទ្ធិត្រូវបង្ហាញជូនគណៈកម្មការដេញថ្លៃឡូត៍នេសាទ មុនពេលដេញថ្លៃ ។

**មាត្រា២៧._**

អ្នកដែលត្រូវបានប្រកាសទទួលស្គាល់ថាជាអ្នកដេញថ្លៃបានជាបណ្ដោះអាសន្ន ត្រូវបង់ប្រាក់ធានាស្ថាពរដោយគិតរួមទាំងប្រាក់ធានាបណ្ដោះអាសន្នផង ឱ្យបានគ្រប់ចំនួន៥០(ហាសិប)ភាគរយនៃថ្លៃឈ្នួលឡូត៍នេសាទដេញថ្លៃបានយ៉ាងយូរបំផុតរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយពេលដេញថ្លៃ។

ប្រាក់ធានាស្ថាពរ គឺសម្រាប់ធានាការគោរពកិច្ចសន្យា ហើយត្រូវបានរក្សាទុកសម្រាប់បង់ថ្លៃឈ្នួលឡូត៍នេសាទបង្គ្រប់នៅចុងរដូវនេសាទទី២។

**មាត្រា២៨._**

ខណ្ឌរដ្ឋបាលជលផលសាមី ត្រូវរៀបចំគ្រប់សំណុំលិខិតអ្នកដេញថ្លៃបានជាបណ្ដោះអាសន្ន និងកំណត់ហេតុនៃការដេញថ្លៃឡូត៍នេសាទ ព្រមទាំងបង្កាន់ដៃបង់ប្រាក់ធានាស្ថាពរ ហើយបញ្ជូនទៅរដ្ឋបាលជលផលថ្នាក់កណ្ដាលជាបន្ទាន់ ដើម្បីពិនិត្យ និងស្នើសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចេញសេចក្ដីសម្រេចទទួលស្គាល់ថាជាអ្នកដេញថ្លៃបានជាស្ថាពរ ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម៤៥(សែសិបប្រាំ)ថ្ងៃ ក្រោយពេលដេញថ្លៃបាន។ ក្រោយពីមានសេចក្ដីសម្រេចនេះ រដ្ឋបាលជលផលថ្នាក់កណ្ដាលត្រូវចេញលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មឡូត៍នេសាទ ឱ្យដល់អ្នកដែលដេញថ្លៃបានយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ។

**មាត្រា២៩._**

គណៈកម្មការដេញថ្លៃឡូត៍នេសាទ ត្រូវចេញលិខិតបញ្ជាក់ជូនអ្នកដេញថ្លៃពុំបាន ដើម្បីយកទៅដកប្រាក់កក់ធានាបណ្ដោះអាសន្នរបស់ខ្លួនវិញ។

**មាត្រា៣០._**

អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ត្រូវបង់ថ្លៃឈ្នួលឡូត៍នេសាទ នៅរតនាគាររាជធានី ខេត្តសាមី តាមពេលវេលាកំណត់ក្នុងសៀវភៅបន្ទុកឡូត៍នេសាទ។ ក្រោយពេលបង់ប្រាក់ថ្លៃឈ្នួលឡូត៍នេសាទ អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវយកបង្កាន់ដៃបង់ប្រាក់មកតម្កល់ទុកនៅខណ្ឌរដ្ឋបាលជលផលសាមីសម្រាប់ផ្ទៀងផ្ទាត់។

**មាត្រា៣១._**

ថ្លៃឈ្នួលឡូត៍នេសាទដេញថ្លៃបាន ឬថ្លៃជួលឡូត៍នេសាទតាមថ្លៃព្រមព្រៀង គឺជាថ្លៃឈ្នួលឡូត៍នេសាទសុទ្ធសាធសម្រាប់ធ្វើអាជីវកម្មនេសាទក្នុងមួយរដូវនេសាទ។ នៅរដូវនេសាទទី២ ក៏ត្រូវបង់ប្រាក់ថ្លៃឈ្នួលឡូត៍នេសាទ ដូចរដូវនេសាទទី១ដែរ។

អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវបង់ពន្ធប៉ាតង់ និងបង់ពន្ធអាករជូនអង្គភាពពន្ធដារ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣២._**

ក្នុងករណីអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ មិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងសៀវភៅបន្ទុករដ្ឋបាលជលផលត្រូវដកហូតសិទ្ធិនេះមកវិញ ហើយត្រូវរៀបចំដេញថ្លៃសាជាថ្មី តាមនីតិវិធីដែលមានចែងក្នុងមាត្រា[illegible] នៃអនុក្រឹត្យនេះ។

ក្នុងអំឡុងមុនពេលធ្វើអាជីវកម្មឡូត៍នេសាទ ក៏ដូចជាក្នុងករណីឡូត៍នេសាទត្រូវបោះបង់ចោល ខណ្ឌរដ្ឋបាលជលផលសាមី ត្រូវទទួលបន្ទុកការពារឡូត៍នេសាទនោះ ដើម្បីរង់ចាំការសម្រេចជាថ្មីពីរដ្ឋបាលជលផល។

## ជំពូកទី៥
## នីតិវិធីនៃការជួលឡូត៍នេសាទតាមការព្រមព្រៀង

**មាត្រា៣៣.-**

ការជួលឡូត៍នេសាទណាមួយតាមការព្រមព្រៀងអាចប្រព្រឹត្តទៅបាន លុះត្រាតែឡូត៍នេសាទនោះមិនមានអតិថិជនដាក់ពាក្យចូលរួមដេញថ្លៃ ក្រោយពេលធ្វើសេចក្តីជូនដំណឹងដូចមានចែងក្នុងមាត្រា១៧ ចំនួន២(ពីរ)លើករួចមក។ ករណីនេះក៏អាចអនុវត្តបាន ចំពោះឡូត៍នេសាទណាដែលអាជីវករនេសាទបោះបង់ចោល ក្នុងពេលកំពុងធ្វើអាជីវកម្មនេសាទដោយគ្មានមូលហេតុ។

ក្នុងករណីគ្មានអ្នកសុំជួលតាមការព្រមព្រៀង ឡូត៍នេសាទនោះត្រូវស្ថិតក្នុងការគ្រប់គ្រងរបស់រដ្ឋបាលជលផល។

**មាត្រា៣៤.-**

រដ្ឋបាលជលផលត្រូវប្រកាសដាក់ជួលឡូត៍នេសាទជាសាធារណៈ និងកំណត់ថ្លៃឈ្នួលឡូត៍នេសាទតាមការព្រមព្រៀង។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានសិទ្ធិជួលឡូត៍នេសាទតាមការព្រមព្រៀង ត្រូវគោរព និងអនុវត្តតាមបណ្តុំចំណុច ២ ៣ ៦ ៧ និង៨ ចំពោះរូបវន្តបុគ្គល និងអនុវត្តបន្ថែមចំណុច ១ ២ ៣ ៤ ចំពោះនីតិបុគ្គល ស្របតាមមាត្រា១២ នៃអនុក្រឹត្យនេះ។

**មាត្រា៣៥.-**

ក្រោយពេលទទួលបានការឯកភាពជួលឡូត៍នេសាទពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរដ្ឋបាលជលផលរួចហើយ អ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទត្រូវគោរព និងអនុវត្តតាមមាត្រា៣០ និងមាត្រា៣១នៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## ការបង់ថ្លៃឈ្នួលនេសាទ

**មាត្រា៣៦.-**

ការធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍នេសាទសិប្បកម្មក្នុងកន្លែងនេសាទបម្រុងនៃដែននេសាទទឹកសាប ឬការធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទក្នុងដែននេសាទសមុទ្រ ត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម និងត្រូវបង់ថ្លៃឈ្នួលនេសាទ និងប្រាក់ពន្ធផ្សេងៗដែលពាក់ព័ន្ធ លើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារ។

**មាត្រា៣៧.-**

ថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទសិប្បកម្មក្នុងកន្លែងនេសាទបម្រុងនៃដែននេសាទទឹកសាប និងថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទក្នុងដែននេសាទសមុទ្រ ដែលត្រូវបានគណនាតាមប្រភេទ ទំហំ ឬចំនួនឧបករណ៍ សម្ភារៈនេសាទ ឬកម្លាំងសេះនៃមធ្យោបាយនេសាទ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំធ្វើអាជីវកម្មនេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៣៨.-**

ចំពោះជនបរទេសដែលទទួលបានការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាលឱ្យធ្វើអាជីវកម្មនេសាទហើយនោះ ការគិតយកថ្លៃឈ្នួលដែននេសាទសមុទ្រ និងបណ្ណលក្ខខណ្ឌផ្សេងៗទៀត ត្រូវកំណត់តាមការព្រមព្រៀងក្នុងកិច្ចសន្យារវាងរដ្ឋបាលជលផលថ្នាក់កណ្តាល និងភាគីបរទេស ដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៧
## ទណ្ឌកម្ម

**មាត្រា៣៩.-**

ប្រាក់ធានាបណ្តោះអាសន្នត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ក្នុងករណីណាមួយដូចខាងក្រោម ៖

- អ្នកមានឈ្មោះចូលដេញថ្លៃឡូត៍នេសាទ អវត្តមានដោយគ្មានមូលហេតុ
- នៅពេលដេញថ្លៃឡូត៍នេសាទបាន អ្នកដេញថ្លៃបានមិនព្រមផ្តិតស្នាមមេដៃលើកំណត់ហេតុដេញថ្លៃ
- ករណីដូចមានចែងក្នុងចំណុច ២ និង ៣ មាត្រា២៥នៃអនុក្រឹត្យនេះ។

**មាត្រា៤០.-**

ប្រាក់ធានាស្ថាពរត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ក្នុងករណីដែលអ្នកទទួលសិទ្ធិកាន់កាប់ឡូត៍នេសាទ ៖

- បោះបង់ឡូត៍នេសាទចោល មុនពេលបញ្ចប់រដូវនេសាទទី២
- មិនព្រមគោរពឱ្យបានត្រឹមត្រូវតាមសៀវភៅបន្ទុកឡូត៍នេសាទ និងតាមបទបញ្ជាក្នុងលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មឡូត៍នេសាទ
- ដូចមាត្រា៨នៃអនុក្រឹត្យនេះ។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៤១.-**

ក្រៅពីឡូត៍នេសាទដែលត្រូវបានកំណត់ដាក់ឱ្យវិនិយោគ ឱ្យដេញថ្លៃជាសាធារណៈ ឱ្យជួលតាមការព្រមព្រៀង ឡូត៍នេសាទទាំងឡាយណាដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលរួចហើយ ត្រូវមានសុពលភាពរហូតដល់ចប់រយៈពេលនៃការប្រគល់សិទ្ធិឱ្យធ្វើអាជីវកម្មនេសាទ ស្របតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា៤២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងគ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដែលមានដែននេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ